**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

* * * * * *

# ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលឯកអគ្គរាជទូតម៉ារ៉ុកប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

នៅព្រឹកថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យ**ឯកឧត្តម** Abdelilah EL HOUSNI ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រម៉ារ៉ុកប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមាននិវេសនដ្ឋាននៅទីក្រុងបាងកក ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅទីស្តីការក្រសួង។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ឯកអគ្គរាជទូតម៉ារ៉ុក** បានប្រគល់ជូនលិខិតដែលចុះហត្ថលេខារួមដោយឯកឧត្តម Nasser Bourita រដ្ឋមន្ត្រីការបរទេសម៉ារ៉ុក និងឯកឧត្តម Jean-Yves Le Drian រដ្ឋមន្ត្រីការបរទេសបារាំង អញ្ជើញ**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី២ ស្តីពីការថែរក្សាសន្តិភាពនៅក្នុងតំបន់នៃប្រទេសនិយាយភាសាបារាំង ដែលគ្រោងនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣-២៤ ខែមេសា ឆ្នាំ២០២០នៅទីក្រុងរ៉ាបា(Rabat)ប្រទេសម៉ារ៉ុក។ ឯកឧត្តម**ឯកអគ្គរាជទូត** បានគូសបញ្ជាក់ថា ការអញ្ជើញចូលរួមរបស់ឯកឧត្តម **ឧបនាយករដ្ឋមន្ត្រី** ក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីនេះ ពិតជាមានសារៈសំខាន់ណាស់ ដោយសារកម្ពុជាបាននិងកំពុងចូលរួមចំណែកយ៉ាងសកម្ម ក្នុងបេសកកម្មរក្សាសន្តិភាពនៅលើពិភពលោក ជាពិសេសនៅតាមប្រទេសមួយចំនួនក្នុងទ្វីបអាហ្វ្រិក ដែលប្រើប្រាស់ភាសាបារាំង ហើយក៏ជាឱកាសដែលអ្នកចូលរួមទាំងអស់ទទួលបានការចែករំលែកបទពិសោធន៍ពីកម្ពុជាផងដែរ។

ជាកិច្ចឆ្លើយតប **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះការអញ្ជើញនេះ និងបានអបអរសាទរចំពោះម៉ារ៉ុក ដែលធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី២នេះ។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ថា ក្នុងករណីទទួលបានការអនុញ្ញាតពី**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ឱ្យចូលរួមសន្និសីទខាងលើ **ឯកឧត្តម** នឹងអញ្ជើញធ្វើជាវាគ្មិន នៅក្នុងវេទិកាជជែកពិភាក្សាកំរិតខ្ពស់ (Débat Général de Haut-Niveau) ហើយនឹងគ្រោងជួបពិភាក្សាទ្វេភាគីជាមួយរដ្ឋមន្ត្រីការបរទេសម៉ារ៉ុក ដើម្បីពិភាក្សាពីការពង្រឹងទំនាក់ទំនងទ្វេភាគីក្នុងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ វប្បធម៌ និងអប់រំ ។ល។ រួមទាំងកិច្ចសហប្រតិបត្តិការពហុភាគីដទៃទៀត ដូចជាការបង្កើនតួនាទីកាន់តែសកម្មរបស់កម្ពុជាជាមួយបណ្តាប្រទេសនិយាយភាសាបារាំង និងការជំរុញកិច្ចសហប្រតិបត្តិការរវាងម៉ារ៉ុក ជាមួយអាស៊ាន

និងអង្គការវេទិកាអ៊ីស្លាម(OIC)។ល។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងមិត្តភាពដ៏ល្អប្រសើរដោយយូរលង់រវាងព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រម៉ារ៉ុក ដែលត្រូវបានបង្កើតឡើងដោយ**អតីតព្រះមហាក្សត្រកម្ពុជា ព្រះបរមរតនកោដ្ឋ** និង**ព្រះចៅហាសាន់ទី២** របស់ម៉ារ៉ុក។

ពាក់ព័ន្ធនឹងការចូលរួមថែរក្សាសន្តិភាពនៅលើពិភពលោក **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា ចាប់ពីឆ្នាំ២០០៦ រហូតដល់បច្ចុប្បន្ន កម្ពុជាបានបញ្ជូនកងកម្លាំងរក្សាសន្តិភាពរបស់ខ្លួនចំនួនជាង៦៥០០នាក់ ទៅបំពេញបេសកកម្មក្រោមឆ័ត្រអង្គការសហប្រជាជាតិ នៅតាមប្រទេសចំនួន៩ នៅទ្វីបអាហ្វ្រិក ដោយក្នុងនោះស្ត្រីមានចំនួនប្រមាណ៣៣០នាក់ ដែលបានធ្វើឱ្យកម្ពុជា ជាប្រទេសបញ្ជូនកងកម្លាំងជាស្ត្រីច្រើនជាងគេលំដាប់ទី២ក្នុងតំបន់អាស៊ាន និងលំដាប់ទី២០នៅលើពិភពលោក។

ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តម**ឯកអគ្គរាជទូត** បានថ្លែងការកោតសរសើរចំពោះគោលនយោបាយរបស់កម្ពុជា ដែលធ្វើឱ្យមានសុខដុមនីយកម្មរវាងអ្នកកាន់សាសនាខុសៗគ្នានៅក្នុងប្រទេស។ ជាការឆ្លើយតប **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានលើកឡើងថា គោលនយោបាយបង្កើតភាពសុខដុមផ្នែកសាសនានេះ ត្រូវបានប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចតេជោ នាយករដ្ឋមន្ត្រី** យកចិត្តទុកដាក់ជាខ្លាំង និងជំរុញការអនុវត្តជាប់ជាប្រចាំ ដោយគ្មានការរើសអើងឡើយ។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានសន្យាថា នឹងនាំយកបទពិសោធន៍ជោគជ័យទាំងនេះរបស់កម្ពុជា ទៅចែករំលែកជាមួយប្រទេសជាមិត្តទាំងអស់ ក្នុងឱកាសអញ្ជើញចូលរួមសន្និសីទនេះផងដែរ៕

-----------------